# សន្តិសុខនៃការកាន់កាប់ដីធ្លី



## របស់សហគមន៍ជនជាតិដើមភាគតិច

# អារម្ភកថា

កម្មសិទ្ធិដីធ្លី ជាកម្មសិទ្ធិមួយមានសារៈសំខាន់បំផុតសម្រាប់ប្រជាពលរដ្ឋ នៃព្រះរាជាណាចក្រកម្ពុជា ជាពិសេស សហគមន៍ជនជាតិដើមភាគតិច។ ហេតុនេះ វាជាការចាំបាច់ណាស់ ដែលពួកគេទាំងអស់ត្រូវធ្វើការសិក្សា និងស្វែងយល់អំពីលិខិតបទដ្ឋានគតិយុត្តផ្សេងៗដែលក្នុងនោះរួមមានច្បាប់ អនុក្រឹត្យ គោលនយោបាយ និងបទបញ្ញាទាំងឡាយដែលពាក់ព័ន្ធទៅនឹងកម្មសិទ្ធិដីធ្លីនេះ។ ដើម្បីជាការចូលរួមចំណែកលើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋ ជាពិសេស សហគមន៍ជនជាតិដើមភាគតិចលើខ្លឹមសារចំបងៗខ្លះនៃលិខិតបទដ្ឋានគតិយុត្តទាំងឡាយ ដែលទាក់ទងនឹងសុវត្ថិភាពនៃការកាន់កាប់ដីធ្លីរបស់សហគមន៍ជនជាតិដើមភាគតិច ឌីភីអេ បានចងក្រងបោះពុម្ពផ្សាយនូវសៀវភៅរូបភាពមួយដែលមានចំណងជើង "សុវត្ថិភាពនៃការកាន់កាប់ដីធ្លីរបស់សហគមន៍ជនជាតិដើមភាគតិច" ។ ដូច្នេះ សៀវភៅរូបភាពនេះ ទោះបីជាវាមិនមែនជាច្បាប់ ប៉ុន្តែវាអាចជាជំនួយស្មារតីមួយសំរាប់សហគមន៍ជនជាតិដើមភាគតិចក្នុងការចូលរួមស្វែងយល់អំពីជំរើសនៃការកាន់កាប់ដីធ្លីសំរាប់សហគមន៍របស់ពួកគេអោយមាននិរន្តរភាព។


បោះពុម្ពខែ មីនា ឆ្នាំ២០១៣



ការិយាល័យឌីភីអេ កម្ពុជា

ផ្ទះលេខ៦៩ហ្សិត , ផ្លូវលេខ៤៥០, ទួលទំពូងII , ភ្នំពេញ កម្ពុជា

ប្រអប់សំបុត្រលេខ ៥ ភ្នំពេញ កម្ពុជា

ទូរស័ព្ទ ៖ (៨៥៥) ២១៦ ៣៦៩/២១៦ ៤៩៥

អ៊ីម៉ែល ៖ dpa.reception@dpacam.org

គេហទំព័រ ៖ www.dpacam.org

ក្រលា និងនី កំពុងរៀបចំទុកដាក់កណ្ដាប់ និងដំណាំផ្សេងៗដែលពួកគេទើបប្រមូលផលបាន។ ខណៈពេលនោះ រចំ និងកាំឡើន បានដើរសំដៅចូលទៅជួបពួកគេ។ បន្ទាប់មកពួកគេបាននាំគ្នាទៅអង្គុយសំរាកនៅលើគ្រែតូចមួយ ដែលនៅក្រោមដើមឈើធំមួយ (នៅចំហៀងផ្ទះរបស់ក្រលា និងនី)។




សួស្តី ក្រលា និងនី។ ម៉េចហើយ តើផលដំណាំនៅឆ្នាំនេះ យ៉ាងម៉េចដែរ?
បានល្អដូចឆ្នាំមុនដែរ ប៉ុន្តែមិនដឹងថាហូបគ្រប់ រឺ មិនគ្រប់ទេ?
តើមូលហេតុអ្វីទៅ?
សមាជិកគ្រួសារខ្ញុំកាន់តែច្រើន ហើយដីចំការខ្ញុំមានតិចតួចប៉ុណ្ណោះ


ចុះដីចំការរបស់ឯង នៅកន្លែងផ្សេងទៀតទៅណាអស់ហើយ?
ចុះឯងម៉េចមិនតវ៉ាទាមទារយកដីឯងមកវិញទេអី
ដីខ្ញុំនៅព្រៃខាងកើត ត្រូវក្រុមហ៊ុនគេឈូសឆាយយកអស់ហើយ ហើយដីនៅក្បែរអូរក៏មានអ្នកមានអំណាចដណ្តើមយកបាត់ដែរ។
ធ្វើម៉េចយើងអាចតវ៉ាឈ្នះគេបានទៅបើខ្ញុំគ្មានអ្វីបញ្ជាក់ថាដីនោះជារបស់ខ្ញុំផងនោះ។
អ្វីដែលខ្ញុំព្រួយខ្លាំង ជាងគេនោះ គឺខ្លាចបាត់បង់ដីដែលកំពុងមានសព្វថ្ងៃនេះ។ បើដូច្នេះមែន ការរស់នៅរបស់គ្រួសារខ្ញុំមិនដឹងទៅជាយ៉ាងណាទេ។


ទាក់ទងនឹងបញ្ហានេះ សហគមន៍យើងទាំងអស់គ្នាក៏ព្រួយដូចជាយើងដែរ។
តើយើងគួរដោះស្រាយបញ្ហានេះដូចម្ដេចទៅ? អញ្ចឹងដើម្បីយល់ច្បាស់ពីបញ្ហានេះម៉េចយើងមិនទៅជួបលោកពុះមេភូមិដើម្បីសួរបញ្ជាក់អោយបាន ច្បាស់ទៅ?



តើអ្នកទាំងអស់គ្នាទៅណាមកណាហ្នឹង?
អូ!គឺថា ពួកខ្ញុំចង់មកជួយលោកពូមេភូមិដើម្បីសួរនាំពីបញ្ហាដីធ្លីនិងការអភិវឌ្ឍផ្សេងៗនៅក្នុងសហគមន៍របស់យើងហ្នឹងណា!


ខ្ញុំយល់ហើយពីការព្រួយបារម្ភរបស់បងប្អូនយើង។ ដោយសារតែបែបនេះហើយ យើងឃើញថាបច្ចុប្បន្ននេះ រាជរដ្ឋាភិបាល បាននិងកំពុងយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការលើកកំពស់ និងផ្តល់សិទ្ធិអោយសហគមន៍ជនជាតិដើមភាគតិចយើងបានចូលរួមក្នុងសកម្មភាពអភិវឌ្ឍន៍ផ្សេងៗ។ ជាក់ស្តែង ក្នុងនោះមានលិខិតបទដ្ឋានគតិយុត្តជាច្រើនត្រូវបានរៀបចំតាក់តែងឡើងដែលមានដូចជាៈ ច្បាប់ភូមិបាលឆ្នាំ២០០១ គោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច គោលនយោបាយស្តីពីការចុះបញ្ជីដីនិងសិទ្ធិប្រើប្រាស់ដីសហគមន៍ជនជាតិដើមភាគតិចនិងបទបញ្ជាលេខ ០១ ជាដើម ដែលទើបនឹងចេញនៅខែ ឧសភា ឆ្នាំ២០១២ ដើម្បីកំណែទំរង់ទៅលើប្រព័ន្ធនៃការគ្រប់គ្រងដីធ្លីនៅទូទាំងប្រទេស។


ចុះផ្អែកទៅតាមច្បាប់ គោលនយោបាយ និងបទបញ្ញាទាំងអស់នេះ តើជនជាតិដើមភាគតិច ដូចជាយើងនេះ មានសិទ្ធិពិសេសអ្វីខ្លះទៅក្នុងការកាន់កាប់ដីធ្លីរបស់យើង?
ត្រូវហើយនី យើងទាំងអស់គ្នាពិតជាមានសិទ្ធិក្នុងការគ្រប់គ្រងដីធ្លី របស់យើងប្រកបដោយចីរភាពមែន។ យោងតាមមាត្រា ២៣ ដល់ មាត្រា២៨ នៃច្បាប់ភូមិបាលឆ្នាំ២០០១ បានចែងយ៉ាងច្បាស់ថា សហគមន៍ជនជាតិដើមភាគតិចយើង គឺមានសិទ្ធិសម្រេចពេញលេញក្នុងការចុះបញ្ជីដីជាកម្មសិទ្ធិ សមូហភាព រឺ ជាកម្មសិទ្ធិឯកជន។



គួរអោយចាប់អារម្មណ៍ណាស់ពុក! តើការចុះបញ្ជីដីទាំងពីរប្រភេទនេះខុសគ្នាយ៉ាងម៉េចខ្លះទៅ? ហើយមួយណាផ្តល់ផលប្រយោជន៍សំរាប់អ្នកភូមិយើងទៅ?
ការចុះបញ្ជីដីទាំងពីរប្រភេទនេះសុទ្ធតែមានអត្ថប្រយោជន៍រៀងៗខ្លួន គឺវាអាស្រ័យទៅលើការចង់បានរបស់សមាជិកសហគមន៍។
លោកពូអាចជួយប្រាប់ខ្ញុំបន្តិចបានទេ ថាតើមានប្រយោជន៍អ្វីខ្លះទៅ?
ដំបូង ពូសូមបកស្រាយពីការចុះបញ្ជីដីជាកម្មសិទ្ធិឯកជន។ ការចុះបញ្ជីដីជាកម្មសិទ្ធិឯកជន គឺជាការស្នើសុំប័ណ្ណកម្មសិទ្ធិស្របច្បាប់ទៅលើដី ដែលមានការទទួលស្គាល់ពីអាជ្ញាធរមូលដ្ឋាន និងស្របទៅតាមបញ្ញត្តិ ដែលបានចែងក្នុងច្បាប់ភូមិបាល។ ក្រោយពីទទួលបានប័ណ្ណកម្មសិទ្ធិស្របច្បាប់រួច ម្ចាស់កម្មសិទ្ធិមានសិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់អាស្រ័យផល និងចាត់ចែងទៅលើដីរបស់ខ្លួន។
ចុះដីប្រភេទណាទើបស្របទៅតាមបញ្ញត្តិដែលចែងក្នុងច្បាប់ភូមិបាលនោះ?


យោងតាមមាត្រា ៣៨ នៃច្បាប់ភូមិបាលបានកំណត់ថា ដើម្បីក្លាយទៅជាកម្មសិទ្ធិលើអចលនវត្ថុ បានលុះត្រាតែមានការកាន់កាប់ដីនោះដោយពិតប្រាកដ គ្មានហិង្សា មានការដឹងឮជាសាធារណៈ និងអាជ្ញាធរមូលដ្ឋានគ្មានការអាក់ខាន និងកាន់កាប់ដីដោយសុចរិត។
បន្ថែមពីលើនេះទៀត នៅពាក់កណ្ដាលឆ្នាំ២០១២ ប្រមុខរាជរដ្ឋា ភិបាលបានដាក់ចេញនូវបទបញ្ជាលេខ ០១ ដើម្បីពង្រឹង និងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច ដោយធ្វើការផ្អាកបណ្ដោះអាសន្ននូវការផ្ដល់សម្បទានដីសេដ្ឋកិច្ច និងការបញ្ចៀសរាល់ផលប៉ះពាល់ដល់ដីធ្លី និងជីវភាពរបស់ប្រជាជន ក្នុងគោលដៅធ្វើឲ្យសម្បទានដីសេដ្ឋកិច្ចទាំងនេះ បានផ្ដល់ប្រយោជន៍ពិតប្រាកដ ជូនដល់ប្រទេសជាតិ និងប្រជាជនប្រកបដោយចីរភាព។


ពិតជាប្រសើរណាស់!
ដូច្នេះ ក្នុងនាមជាម្ចាស់កម្មសិទ្ធិលើដីឯកជន
យើងមានសិទ្ធិពេញលេញក្នុងការប្រើប្រាស់
អាស្រ័យផល និងចាត់ចែងដូចជាលក់ ឬជួលបាន។
ចុះចំណែកកម្មសិទ្ធិសមូហភាព?
យោងតាមមាត្រា៤
នៃអនុក្រឹត្យស្តីពី នីតិវិធី នៃ
ការចុះបញ្ជីដីសហគមន៍ជនជាតិដើម
ភាគតិច បានកំណត់ថា កម្មសិទ្ធិសមូហភាព
សំដៅដល់ដីធ្លី ដែលជាកម្មសិទ្ធិរួម
របស់សហគមន៍ជនជាតិដើមភាគតិចមួយក្រុម
ហើយកម្មសិទ្ធិនេះ មិនមែនជា
កម្មសិទ្ធិឯកជនដោយឡែកៗរបស់សមាជិក
សហគមន៍នោះឡើយ។
សមាជិកម្នាក់ៗ ឬ គ្រួសារនីមួយៗ
នៃសហគមន៍ គ្មានសិទ្ធិចាត់ចែងដីជា
កម្មសិទ្ធិសមូហភាពនេះទេ។


ស្តាប់ទៅគួរអោយចាប់អារម្មណ៍ដែរ ប៉ុន្តែបើយើងចុះបញ្ជីដីជាសមូហភាព មិនមែនន័យថា យើងបាត់បង់សិទ្ធិគ្រប់គ្រងដីទៅហើយឬ?
មិនដូច្នោះនោះទេកម្មសិទ្ធិសមូហភាព មានគោលការណ៍ច្បាស់លាស់របស់គេ។ សហគមន៍គឺជាម្ចាស់លើដីកម្មសិទ្ធិសមូហភាព ហើយ សមាជិកទាំងអស់គ្នាមានសិទ្ធិប្រើប្រាស់ និង គ្រប់គ្រងដីធ្លីតាមប្រពៃណីរបស់ពួកគេនីមួយៗ។ ដោយឡែក គ្រួសារនីមួយៗមានសេរីភាពក្នុងការទទួល ប្រយោជន៍ពីដីនៅក្នុងសហគមន៍ ដោយផ្អែកតាមប្រពៃណី របស់ខ្លួន ដោយមិនមានអ្នកតូច អ្នកធំក្នុងសហគមន៍ទេ។ នេះមានន័យថា គឺគ្មានសមាជិកណាមួយនៃ សហគមន៍មានសិទ្ធិអំណាចធំជាង ឬ ទៅចាត់ចែងគ្រួសារសមាជិកណាមួយទៀត ក្នុងសហគមន៍ទេ។
តើសិទ្ធិសំខាន់ៗនៃកម្មសិទ្ធិសមូហភាពមានអ្វីខ្លះ?


សហគមន៍ជនជាតិដើមភាគតិចមានសិទ្ធិលើកម្មសិទ្ធិសមូហភាពដូចដែលបានទទួលស្គាល់ដោយច្បាប់រួមមានសិទ្ធិបន្តមរតក សិទ្ធិប្រើប្រាស់និងសិទ្ធិអាស្រ័យផល។ ក៏ប៉ុន្តែកម្មសិទ្ធិសមូហភាពរបស់ជនជាតិដើមភាគតិចមិនអាចជាកម្មវត្ថុនៃការលក់ ដូរ ឬ ផ្ទេរអោយអ្នកក្រៅសហគមន៍បានឡើយ លើកលែងតែករណីដែលសមាជិកណាមួយនៃសហគមន៍ចាកចេញពីសហគមន៍នោះសហគមន៍អាចនឹងត្រូវផ្ទេរជាពិសេសអោយពួកគេនូវចំណែកសមស្របមួយនៃដីដែលត្រូវប្រើដោយសហគមន៍ និងស្ថិតលើចំណែកដីឯកជនរបស់រដ្ឋ។
ក្រៅពីសិទ្ធិទាំងនេះ តើយើងមានសិទ្ធិធ្វើអ្វីខ្លះទៀតទៅ?


ក្រៅពីនេះទៀត គឺយើងទាំងអស់គ្នាមានសិទ្ធិរួមគ្នាការពារ ដីសហគមន៍,មានសិទ្ធិប្តឹងតវ៉ាទាមទារដីសហគមន៍មកវិញពេលមាន ការរំលោភយកដីសហគមន៍ពីអាជ្ញាធរ ក្រុមហ៊ុន និងអ្នកខាងក្រៅសហគមន៍, មានសិទ្ធិ រារាំង ឬ ហាមឃាត់មិនអោយសមាជិកណាមួយលក់ដីសមូហភាពទាំងឡាយរបស់ សហគមន៍ ដែលទទួលស្គាល់តាមផ្លូវច្បាប់។ ជាងនេះទៅទៀត គឺសហគមន៍មានសិទ្ធិ ទាមទារដីដែលបានលក់ ឬ ចាប់យកដោយខុសច្បាប់មកវិញអោយសហគមន៍ផងដែរ។ ដោយឡែក តាមមាត្រា ២៨នៃច្បាប់ភូមិបាលបានកំណត់ច្បាស់លាស់ថា " គ្មានអាជ្ញាធរណាមួយ ក្រៅពីសហគមន៍ អាចទទួលបានសិទ្ធិលើអចលនវត្ថុរបស់ ជនជាតិដើមភាគតិចបានឡើយ "។
អរគុណលោកពូច្រើនណាស់ ដែលបាន និយាយនិងពន្យល់ប្រាប់ពួកខ្ញុំទាំងអស់គ្នាអោយ បានយល់សារៈប្រយោជន៍ផ្សេងៗគ្នារវាងការចុះ បញ្ជីដីជាកម្មសិទ្ធិសមូហភាពនិងជា កម្មសិទ្ធិឯកជននោះ។
ពិតមែនហើយ !


ល្អណាស់ក្មួយៗ។
ពូសប្បាយចិត្តណាស់នៅពេលដែលអ្នក
ទាំងអស់គ្នាមានគំនិតចង់ដឹង
និងចង់ទទួលព័ត៌មាន
ផ្សេងៗបែបនេះ។
អញ្ចឹងយើងទាំងអស់គ្នាត្រូវហៅ
អ្នកភូមិយើងទាំងអស់មកពិភាក្សាគ្នាពី
រឿងសហគមន៍របស់យើងថាតើពួកគាត់
ចង់ធ្វើការចុះបញ្ជីដីជាកម្មសិទ្ធិ
សមូហភាព រឺ កម្មសិទ្ធិឯកជន។


ម៉ោ! ក្មួយៗ ហូបបាយជុំគ្នាជាមួយនឹងពូនិងមីងអ្វី?
អា...អាឡៃទៀងតែជជែកគ្នាឥឡូវនេះដល់ម៉ោងហូបបាយថ្ងៃត្រង់ស្រេច។ តោះមកហូបបាយជុំគ្នា!
អរគុណច្រើនពូមេភូមិ សូមអញ្ជើញពូពិសារចុះ។ ពួកខ្ញុំគិតថាសូមលា ពូមេភូមិទៅផ្ទះវិញដែរហើយ។
អ្នកទាំងអស់បែកគ្នាពីផ្ទះពូមេភូមិ ហើយចាកចេញទៅផ្ទះរៀងៗខ្លួន។

# ឯកសារយោង

- ច្បាប់ភូមិបាលឆ្នាំ២០០១
- អនុក្រឹត្យលេខ៨៣ អនក្រ/បក/៩.០៦.២០០៩ របស់រាជរដ្ឋាភិបាលកម្ពុជាស្តីពី នីតិវិធីនៃការចុះបញ្ជីដីរបស់សហគមន៍ជនជាតិដើមភាគតិច
- គោលនយោបាយជាតិស្តីពី ការអភិវឌ្ឍជនជាតិដើមភាគតិច ឆ្នាំ២០០៩
- គោលនយោបាយស្តីពីការចុះបញ្ជី និងសិទ្ធិប្រើប្រាស់ដីសហគមន៍ជនជាតិដើមភាគតិចនៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩
- បទបញ្ជាលេខ ០១ បប របស់រាជរដ្ឋាភិបាលកម្ពុជាស្តីពី វិធានការពង្រឹង និងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច ឆ្នាំ២០១២

DPA

DEVELOPMENT AND PARTNERSHIP IN ACTION

Trōcaire

Oxfam Novib

European Union